ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2019, 15:30
CMS/CFO: Sann Rada

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវុឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Maureen HARDING CLARK** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

---

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេចលេខ E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនប្រឆាំងនឹងសាលក្រមប្រកាស នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

---

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS (បម្រុង)

**សហមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

01625059



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩ ("តុលាការកំពូល" និង "អ.វ.ត.ក") បានទទួលសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សំណើរបស់ ខៀវ សំផន")[១]។

## I. **សាវតារ**

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ដោយផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ ដោយបានសម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបនៃសំអាងហេតុរបស់ខ្លួន និងបានបញ្ជាក់ថា សំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់នឹងចេញនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរនៅក្នុងពេលសមស្របខាងមុខ[២]។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីសាលក្រមជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩[៣]។

២. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខៀវ សំផន បានដាក់"បណ្តឹងសាទុក្ខភ្លាមៗ"ប្រឆាំងនឹងសាលក្រមដោយយោងទៅលើកំហុសផ្នែកនីតិវិធី និងគ្មានសំអាងហេតុ[៤]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ

[១] សំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E463/1/4 ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

[២] *សូមមើល* ប្រតិចារឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ឯកសារ E1/529.1 ទំព័រ ២ (ជួរ ១ ដល់ ៩)។

[៣] អង្គជំនុំជម្រះសាលាដំបូង សាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ("សាលក្រម")។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដោយសារសាលក្រមបានដាក់នៅក្រៅម៉ោងដាក់ឯកសារផ្លូវការ សេចក្តីជូនដំណឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃធ្វើការបន្ទាប់ គឺ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩៖ សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ឯកសារ F43 ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១២។

[៤] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E463/1 ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ (បានជូនដំណឹងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨)។

២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា បណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន មិនអាចទទួលយកបានទេ (“សេចក្តីសម្រេចដែលរងការជំទាស់”)។

៣. នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៩ លោក ខៀវ សំផន បានដាក់សំណើរបស់គាត់ដោយសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើមោឃភាពសេចក្តីសម្រេចដែលរងការជំទាស់ ដោយសារចៅក្រម RAPOZA មិនទាន់ត្រូវបានចាត់ជាចៅក្រមមានសិទ្ធិចូលរួមធ្វើសេចក្តីសម្រេច នៅពេលចេញសេចក្តីសម្រេចរងការជំទាស់។ ខៀវ សំផន បានស្នើសុំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចថ្មីមួយលើបណ្តឹងសាទុក្ខរបស់គាត់ដោយក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសមាសភាពត្រឹមត្រូវ[៥]។ សំណើរបស់ ខៀវ សំផន បានជូនដំណឹងនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩។ សហព្រះរាជអាជ្ញាពុំបានឆ្លើយតបលើអង្គសេចក្តីទៅនឹងសំណើរបស់ ខៀវ សំផន ទេ[៦]។ ភាគីផ្សេងទៀតពុំបានឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន ដែរ។

## II. <u>ការពិភាក្សា</u>

៤. អង្គជំនុំជម្រះរម្លឹកថា នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១២ ចៅក្រម RAPOZA ត្រូវបានតែងតាំងជាចៅក្រមបម្រុងនៅអង្គជំនុំជម្រះតុលាការកំពូលដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់កម្ពុជា បន្ទាប់ពីមានការតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ[៧]។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ លោកស្រីចៅក្រម Agnieszka KLONOWIECKA-MILART បានលាឈប់ពីមុខតំណែងជាចៅក្រមអន្តរជាតិពេញសិទ្ធិនៅអង្គជំនុំជម្រះតុលាការកំពូល[៨]។ ក្នុងអំឡុងពេលនេះ ការតែងតាំងចៅក្រម RAPOZA បានបន្តដំណើរការនៅឡើយ[៩]។ គាត់បានស្បថចូលកាន់មុខតំណែងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។ នៅពេលចេញសេចក្តីសម្រេចដែលរងការជំទាស់នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ ចៅក្រម RAPOZA បានទទួល

[៥] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៥-៨, ១៣-១៤, ២២។

[៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសាលក្រមប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E463/1/4/1 ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ២ (កត់សម្គាល់ថា “សហព្រះរាជអាជ្ញាមិនត្រូវបានអនុញ្ញាតឱ្យដឹងអំពីព័ត៌មាន ទាក់ទងទៅនឹងការកំណត់អង្គសេចក្តីនៃសំណើ [របស់ ខៀវ សំផន]”)។

[៧] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា “សេចក្តីប្រកាសព័ត៌មាន៖ ការតែងតាំងចៅក្រមអន្តរជាតិនៅអង្គជំនុំជម្រះតុលាការកំពូល”ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ គេហទំព័រ https://eccc.gov.kh/en/articles/appointment-international-judges-supreme-court-chamber។

[៨] *សូមមើល*សេចក្តីសម្រេចរងការជំទាស់។

[៩] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ អ.វ.ត.ក) មាត្រា ១២។

ការតែងតាំងជាផ្លូវការ និងបានស្បថចូលកាន់មុខតំណែងជាចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលរួចហើយ។

៥. ពាក់ព័ន្ធនឹង "ដីកាចាត់តាំង"[១០] ខៀវ សំផន មានការយល់ខុសចំពោះកាលប្បវត្តិដែលអង្គជំនុំជម្រះចេញដីកាចាត់តាំង និងសេចក្តីសម្រេចដែលរងការជំទាស់។ ខៀវ សំផន យល់ច្រឡំការទទួលបានសេចក្តីសម្រេចដែលរងការជំទាស់ពីមន្ត្រីគ្រប់គ្រងសំណុំរឿង ជាមួយនឹងសេចក្តីជូនដំណឹងនៃដីកាចាត់តាំងតាមប្រព័ន្ធអេឡិចត្រូនិក ដែលបណ្តាលឲ្យមានការសន្និដ្ឋានដោយមិនត្រឹមត្រូវថា សេចក្តីសម្រេចដែលរងការជំទាស់ត្រូវបានចេញមុនដីកាចាត់តាំង[១១]។ ដីកាចាត់តាំងត្រូវបានដាក់ក្នុងសំណុំរឿងដោយក្រឡាបញ្ជីរបស់អង្គជំនុំជម្រះជាពីរភាសា ហើយមន្ត្រីគ្រប់គ្រងសំណុំរឿងបានទទួលជាភាសាខ្មែរ នៅវេលាម៉ោង ១:៤៦ រសៀល នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៩ និងជាភាសាអង់គ្លេស នៅវេលាម៉ោង ១:៤៧ រសៀល។ បន្ទាប់មក មន្ត្រីគ្រប់គ្រងសំណុំរឿងបានទទួល និងបោះត្រាទៅលើសេចក្តីសម្រេចដែលរងការជំទាស់នៅវេលាម៉ោង ២:៥២ រសៀល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ហើយមួយនាទីក្រោយមក គាត់បានទទួល និងបោះត្រាលើសំណៅជាភាសាអង់គ្លេស។ ដីកាចាត់តាំង និងសេចក្តីសម្រេចដែលរងការជំទាស់បានជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដល់ភាគីនៅថ្ងៃដដែលនោះ នៅវេលាម៉ោង ៣:០៧ រសៀល និង វេលាម៉ោង ៣:១៧ រសៀល បន្តបន្ទាប់គ្នា។

៦. ការលើកឡើងបែបស្មានៗរបស់ ខៀវ សំផន អំពីលក្ខណៈ ពេលវេលា និងខ្លឹមសារនៃការពិភាក្សារបស់ចៅក្រមជុំវិញសេចក្តីសម្រេចដែលរងការជំទាស់[១២] ត្រូវទុកជាអសារបង់ ចំពោះចេតនា និងគោលបំណងទាំងអស់។ ការពិភាក្សារបស់ចៅក្រមអង្គជំនុំជម្រះធ្វើឡើងដោយសម្ងាត់[១៣]។ នៅពេលអង្គជំនុំជម្រះចេញសេចក្តីសម្រេចណាមួយ សេចក្តីសម្រេច ដីកា ឬសាលដីកាជាលាយលក្ខណ៍អក្សរនោះត្រូវចេញជាពីរភាសា ដូចបានតម្រូវដោយមាត្រា ៧ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារ ដោយមានការពិនិត្យឡើងវិញ ចុះហត្ថលេខា បោះត្រា និងដាក់ជូនភាគី។ ជារួម ដំណើរការនេះត្រូវចំណាយពេលវេលាជាច្រើនដែលលើសពីតារាងពេលវេលាដែល ខៀវ សំផន បានលើកឡើង។ កត្តានានាដូចជា ចិរវេលានៃការដាក់សេចក្តីសម្រេចទៅក្នុងសំណុំរឿង និងការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកគឺជាបញ្ហាតូចតាច

---

[១០] ដីកាចាត់តាំងចៅក្រមបម្រុង ឯកសារ F38 ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩។

[១១] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៧ ដល់ ៨។

[១២] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៩ ដល់ ១១ និង ១៤។

[១៣] វិធាន ៩៦(១) និង ១៤០*ស្ទួន* នៃវិធានផ្ទៃក្នុង។

ផ្នែករដ្ឋបាល មិនពាក់ព័ន្ធទៅនឹងដំណើរការផ្លូវតុលាការរបស់អង្គជំនុំជម្រះតុលាការកំពូលទេ ហេតុនេះ ពុំមានអានុភាពទៅលើសេចក្តីសម្រេចផ្នែកអង្គសេចក្តីនៅក្នុងករណីនេះឡើយ។

៧. អង្គជំនុំជម្រះយល់ឃើញថា សំណើរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រ។

## III. <u>ផ្នែកសម្រេចសេចក្តី</u>

៨. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**បដិសេធ**សំណើរបស់ ខៀវ សំផន។

**រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៩**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**